**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 29-Apr-2013, 15:57
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមពេលវេលាសម្រាប់**
**សួរដេញដោលសាក្សី TCW-277 និង TCW-84**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក គង់ សំអុន
លោកស្រី Anta GUISSE
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ២១(១), ៨៥, ៩១, ៩១*ស្ទួន* និង៩២ សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គជំនុំជម្រះ អនុញ្ញាតបន្ថែមពេលវេលាដល់គូភាគីសម្រាប់សួរដេញដោលសាក្សី TCW-277 និង TCW-84 (“សាក្សី”) ពីមួយម៉ោងកន្លះ ទៅបីម៉ោង។ ការណ៍នេះធ្វើឡើងដោយមានមូលដ្ឋានថា សាក្សីទាំងពីររូបនេះ ទំនងជាមានចំណេះដឹងដោយផ្ទាល់អំពីអង្គហេតុនានាដែលនឹងផ្តល់នូវភស្តុតាងពាក់ព័ន្ធ និងអាចជឿទុកចិត្តបានអំពីអង្គហេតុជាក់ស្តែងផ្សេងទៀតក្នុងសំណុំរឿងនេះ លើសពីអត្តចរិករបស់ជនជាប់ចោទ។ បញ្ហាបន្ថែមទាំងនោះទំនងជានឹងជួយដល់អង្គជំនុំជម្រះ នៅក្នុងការស្វែងរកការពិតអំពីការចោទប្រកាន់នានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

២. ច្បាប់ អ.វ.ត.ក និងទម្លាប់នៃការអនុវត្តនៅថ្នាក់អន្តរជាតិកំណត់ថា ភាគីមួយអាចស្នើដេញដោលសាក្សីណាម្នាក់បានលើគ្រប់បញ្ហាទាំងអស់ដែលស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះ កាលណាសាក្សីរូបនោះទំនងជានឹងផ្តល់ភស្តុតាងពាក់ព័ន្ធនិងដែលអាចជឿទុកចិត្តបានចំពោះបញ្ហាទាំងនោះ។ ចំណុចដែលពាក់ព័ន្ធនៃការសួរដេញដោលនេះរួមមាន ភស្តុតាងអំពីអង្គហេតុដែលបានកើតឡើងនៅមុន ឬក្រោយវិសាលភាពនៃពេលវេលានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម្បីកំណត់អំពី៖ (i) ប្រវត្តិនិងបរិបទនៃបទឧក្រិដ្ឋ។ (ii) អំពើប្រព្រឹត្តស្រដៀងគ្នាពីមុនរបស់ជនជាប់ចោទ។ (iii) ការប្រព្រឹត្តិឧក្រិដ្ឋកម្មស្រដៀងគ្នា និង (iv) បុរេអត្ថិភាព ឬ ចរិកលក្ខណៈបន្តបន្ទាប់ នៃធាតុផ្សំណាមួយនៃបទឧក្រិដ្ឋឬលក្ខខណ្ឌតម្រូវផ្នែកច្បាប់អំពីទម្រង់នៃការទទួលខុសត្រូវ ដូចជាភស្តុតាងបញ្ជាក់ ពីផែនការឧក្រិដ្ឋជាបន្តបន្ទាប់នៅក្នុងបរិបទនៃសហកម្មឧក្រិដ្ឋកម្មរួមជាដើម។ ដោយពិចារណាលើព័ត៌មានដែលគេអាចរកបានទាំងនេះ ទោះបីជាមានកំណត់ព្រំដែនក៏ដោយទាក់ទងនឹងចំណេះដឹងដោយផ្ទាល់របស់សាក្សីទាំងពីររូបនេះ សហព្រះរាជអាជ្ញាសន្និដ្ឋាន ដោយមានសំអាងហេតុបញ្ជាក់ខាងក្រោមថាការបន្ថែមពេលវេលា គឺស្ថិតក្នុងផលប្រយោជន៍នៃយុត្តិធម៌។

## II. ប្រវត្តិនីតិវិធី និងអង្គហេតុ

៣. នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង(“អង្គជំនុំជម្រះ”) បានបង្គាប់ឲ្យសាក្សី TCW-277 និង TCW-84 ចូលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះតាមរយៈប្រព័ន្ធសោតទស្សន៍ អនុលោមតាមវិធាន២៦[1]។ អង្គជំនុំជម្រះបានបញ្ជាក់ថា សាក្សីទាំងនេះ “នឹងផ្តល់សក្ខីកម្មត្រឹមតែអំពីអត្តចរិករបស់ជនជាប់ចោទប៉ុណ្ណោះ[2]” និងបានពិចារណាថា “ជាការពុំចាំបាច់ដើម្បីនាំសាក្សីទាំង ០២រូបនេះ[...] មកកម្ពុជា គ្រាន់តែដើម្បីស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងអត្តចរិកសម្រាប់រយៈពេល

[1] **E236/5/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ “សេចក្តីសម្រេចស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-277 និង TCW-84 ពាក់ព័ន្ធនឹងអត្តចរិតរបស់ ខៀវ សំផន តាមរយៈប្រព័ន្ធសោតទស្សន៍”, ២៤ មេសា ២០១៣។

[2] **E236/5/4** *ដដែលដូចខាងលើ*។

ដ៏ខ្លីដូច្នេះទេ"[3]។ អង្គជំនុំជម្រះ បានលៃលកពេលវេលាផ្តល់ជូនមួយម៉ោងកន្លះដល់គូភាគីទាំងអស់ ដើម្បីសួរដេញដោលសាក្សីម្នាក់ៗ[4]។ តាមបទដ្ឋាននៃទម្លាប់ក្នុងការអនុវត្តរបស់អង្គជំនុំជម្រះ រយៈពេលពាក់កណ្តាលនៃពេលវេលាសរុបដែលបានផ្តល់ជូននេះ មានន័យថា៤៥នាទី នឹងផ្តល់ឲ្យសហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំណែកឯពាក់កណ្តាលទៀតនឹងផ្តល់ឲ្យក្រុមមេធាវីការពារក្តីទាំងពីររួមបញ្ចូលគ្នា។

៤. សាក្សីទាំងពីររូប ត្រូវបានមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ("មេធាវីការពារក្តី") ស្នើឲ្យអង្គជំនុំជម្រះស្តាប់សវនាការ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១១។ ពាក់ព័ន្ធនឹងសាក្សី TCW-277 "សេចក្តីសង្ខេបនៃសក្ខីកម្មដែលបានស្នើឡើង" ដែលបានផ្តល់ជូនដោយមេធាវីការពារក្តី ថ្លែងថា៖

> [សាក្សី TCW-277] *បានស្គាល់លោក ខៀវ សំផន នៅទីក្រុងប៉ារីស ចាប់ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៥៨ និងក្នុងឆ្នាំ១៩៥៩ អំឡុងពេលសិក្សានៅប្រទេសបារាំង។ គាត់បានចូលរួមនៅក្នុងការជជែកគ្នាមួយនៅប៉ារីស ដែលបានផ្តល់ដោយលោក ខៀវ សំផន និងក៏ស្ថិតនៅក្នុងគោលជំហរមួយនិយាយអំពីសំណើសុំការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចរបស់លោក ខៀវ សំផន គោលជំហរខាងនយោបាយរបស់គាត់ និងប្រជាប្រិយភាពរបស់គាត់។ ដោយបានរៀបការជាមួយស្ត្រីខ្មែរមួយរូបក្នុងឆ្នាំ១៩៦៧* [សាក្សី TCW-277] *គាត់បានបាត់ដានក្រុមគ្រួសារខាងប្រពន្ធរបស់គាត់ និងមិត្តភ័ក្តិរបស់គាត់ជាច្រើននាក់ក្នុងរបបខ្មែរក្រហម។ ដោយសារវិសាលភាពនៃចំណេះដឹង និងឋានៈរបស់គាត់ក្នុងនាមជាជនរងគ្រោះដោយប្រយោលមួយរូបនៃរបបខ្មែរក្រហម* [សាក្សី TCW-277] *នឹងបង្ហាញខ្លួនទាំងក្នុងនាមជាសាក្សីនៃសម័យកាលនោះផង និងជាសាក្សីអត្តចរិកផង*[5]។

៥. ពាក់ព័ន្ធនឹងសាក្សី TCW-84 មេធាវីការពារក្តីថ្លែងថា៖ *"គាត់បានស្គាល់ ខៀវ សំផន តាំងពីទសវត្សរ៍១៩៦០ ជាបញ្ញវន្តម្នាក់ដែលមានឧត្តមគតិ និងសុចរឹតភាព ជាអ្នកដែលមានការយកចិត្តទុកដាក់ចំពោះប្រទេសរបស់គាត់។ គាត់នឹងផ្តល់សក្ខីកម្មអំពីអត្តចរិករបស់គាត់នៅពេលនោះ និងនៅក្រោយឆ្នាំ១៩៧៩"*[6]។

៦. មេធាវីការពារក្តីបញ្ជាក់ថា សាក្សីទាំង ០២រូប នឹងផ្តល់សក្ខីកម្មដែលពាក់ព័ន្ធនឹងផ្នែកនានានៃដីកាដំណោះស្រាយ ទាក់ទងនឹងអត្តចរិករបស់ជនជាប់ចោទ ខៀវ សំផន។ មេធាវីការពារក្តីបានកំណត់អត្តសញ្ញាណបន្ថែមទៀតថា សក្ខីកម្មសាក្សី TCW-277 ដែលបានស្នើឡើង គឺមានភាពពាក់ព័ន្ធនឹង "តួនាទី និងមុខងាររបស់" របស់ជនជាប់ចោទ ខៀវ សំផន ហើយសក្ខីកម្មសាក្សី TCW-84 ដែល

---

[3] **E236/5/4** *ដដែលដូចខាងលើ*។

[4] **E236/5/4** *ដដែលដូចខាងលើ*។

[5] **E9/11.2** ឧបសម្ព័ន្ធ ១៖ សេចក្តីសង្ខេបសាក្សីពាក់ព័ន្ធនឹងចំណុចផ្សេងៗនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ - ខៀវ សំផន, ១៥ មីនា ២០១១, ត្រង់ទំព័រទី២ [សង្កត់ន័យត្រង់អក្សរទ្រេត]។

[6] **E9/11.2** *ដដែលដូចខាងលើ* ត្រង់ទំព័រទី១។

បានស្នើឡើងមានភាពពាក់ព័ន្ធនឹង "ការរកឃើញផ្នែកអង្គហេតុ" ទាក់ទងនឹងប្រវត្តិបក្សកម្មុយនីស្តកម្ពុជា" នៃព្រឹត្តិការណ៍នានាដូចបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ[7]។

៧. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ ក្នុងការឆ្លើយតបទៅនឹងការជំទាស់របស់សហព្រះរាជអាជ្ញា ក្នុងការទទួលយកលិខិតមួយច្បាប់ដែលនិពន្ធដោយសាក្សី TCW-277 ដោយពុំមានសក្ខីកម្មផ្ទាល់មាត់របស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ មេធាវីការពារក្តីបានថ្លែងថា៖ [...] *បុគ្គលទាំងនេះដែលបានស្គាល់គាត់ជាច្រើនឆ្នាំ និង[...] ដែលអាចផ្តល់សក្ខីកម្មអំពីបុគ្គលិកលក្ខណៈ របស់គាត់ និងអំពី__បរិបទនៃការរស់នៅ និងធ្វើការងារ__ ដែលចំណុចទាំងអស់នេះមាន សារសំខាន់បំផុតចំពោះយើង ដូច្នេះយើងខ្ញុំសូមស្នើឱ្យកោះហៅបុគ្គលទាំងនេះមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ* [...][8]។ មេធាវីការពារក្តីបានបន្តទៀតថា៖ *នេះជាបញ្ហាដែលពាក់ព័ន្ធនឹងការគោរពសិទ្ធិក្នុងការការពារខ្លួន។ យើងបានបញ្ជាក់យ៉ាងច្បាស់លាស់ថា __យើងកំពុងតែនិយាយទាំងអំពីបរិបទប្រវត្តិសាស្ត្រនិងទាំង__ បុគ្គលិកលក្ខណៈ __របស់ខៀវ សំផន__។ យើងមិនបានព្យាយាម បោកប្រាស់នរណាម្នាក់ចំពោះបញ្ហានេះទេ ហើយនិងទិដ្ឋភាពលើចំណុចនោះដែលមាន ដែលបានរៀបរាប់ដោយសាក្សីទាំងនេះ គឺស្ថិតនៅក្នុងបរិបទប្រវត្តិសាស្ត្រ* [...][9]។

៨. នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះបានស្តាប់អំណះអំណាងផ្ទាល់មាត់ ស្តីពីវិសាលភាពនៃការសួរដេញដោល "សាក្សីអត្តចរិក" ដោយចៅក្រម Lavergne បានផ្តល់ការណែនាំដល់ភាគីដូចតទៅថា៖ *"សាក្សីទាំងនេះត្រូវបានចាត់ទុកថា សាក្សីអត្តចរិក ហើយចំពោះអ្វីដែលខ្ញុំប្រមូលបាន ខ្ញុំគិតថា អ្នករាល់គ្នាក៏ឯកភាពថា សាក្សីទាំងនេះក៏អាចមានសំណួរផ្សេងៗទៀតដែលនឹងត្រូវសួរពួកគាត់ពាក់ព័ន្ធនឹងអង្គហេតុនានាដែលមាននៅក្នុងដីកាដំណោះស្រាយ ហើយនឹងពាក់ព័ន្ធគ្រប់* [...] *ជនជាប់ចោទទាំងអស់*[10]។ ទាំងសហព្រះរាជអាជ្ញា[11] និងទាំងមេធាវីការពារក្តី អៀង សារី[12] បាន យល់ឃើញស្រដៀងគ្នា ។

## III. ច្បាប់ជាធរមាន

### *ក. គោលការណ៍ទូទៅពាក់ព័ន្ធនឹងការសួរដេញដោលសាក្សី*

៩. គោលការណ៍ជាមូលដ្ឋានដែលណែនាំអំពីគុណភាព និងបរិមាណនៃការសួរដេញដោលសាក្សីដែលអនុញ្ញាតនៅ អ.វ.ត.ក និងនៅសាលាក្តីអន្តរជាតិដទៃទៀត គឺលទ្ធភាពនៃការសួរដេញដោលដើម្បី

---

[7] **E9/11.2** *ដដែលដូចខាងលើ* ត្រង់ទំព័រទី១-២។

[8] **E1/161.1** ប្រតិចារឹក, ២១ មករា ២០១៣ ត្រង់ទំព័រទី៣៦ បន្ទាត់ទី១៨-២២ [សង្កត់ន័យត្រង់អក្សរទ្រេត]។

[9] **E1/161.1** ប្រតិចារឹក, ២១ មករា ២០១៣ ត្រង់ទំព័រទី៣៧ បន្ទាត់ទី៤-៩ [សង្កត់ន័យត្រង់អក្សរទ្រេត]។

[10] **E1/171.1** ប្រតិចារឹក, ១៨ កុម្ភៈ ២០១៣ ត្រង់ទំព័រទី៦៦ បន្ទាត់ទី២-៦។

[11] **E1/171.1** *ដដែលដូចខាងលើ* ត្រង់ទំព័រទី៧១ បន្ទាត់ទី១០-២២។

[12] **E1/171.1** *ដដែលដូចខាងលើ* ត្រង់ទំព័រទី៧០ បន្ទាត់ទី១៧-២២ និងទំព័រទី៧៤ បន្ទាត់ទី១០-១៨។

នាំទៅរកការពិតដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមរបៀបមួយដ៏មានប្រសិទ្ធិភាព។ វិធាន៩០(ច) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការ ICTY, ICTR និង SCSL អនុញ្ញាតឲ្យអង្គជំនុំជម្រះ ដាក់ការកំណត់ស្តីពីការសួរដេញដោលដើម្បីធានាឲ្យបានក្នុងការនាំមកនូវ ការស្វែងរកការពិត និងដើម្បីបញ្ចៀសការប្រើប្រាស់ពេលវេលាមិនចាំបាច់[13]។ បទបញ្ជាផ្ទៃក្នុងរបស់តុលាការ ICC ក៏បាន អនុម័តយកអភិក្រមស្រដៀងគ្នានេះដែរ[14]។

១០. ពេលវេលាដែលបានបែងចែកសម្រាប់សួរដេញដោលសាក្សីទាំង ០២រូបនេះ អាចត្រូវបានបន្ថែម ប្រសិនបើស្ថិតក្នុងផលប្រយោជន៍នៃយុត្តិធម៌។ នៅចំពោះមុខតុលាការ ICTY ជាឧទាហរណ៍នៅក្នុងរឿងក្តី *Stanisic* ខាងអយ្យការបានតវ៉ាសុំពេលវេលាបន្ថែមដើម្បីធានាថា "គ្រប់ប្រធានបទទាំងអស់ដែលពាក់ព័ន្ធនឹងបញ្ហានានានៃសំណុំរឿងត្រូវបានពិនិត្យពិច័យ ដើម្បីផ្តល់នូវតម្លៃដែលពាក់ព័ន្ធ និងតម្លៃភស្តុតាងនីយភាពចំពោះធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ"[15]។ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមានការបន្ថែមពេលវេលា សម្រាប់សួរដេញដោលសាក្សីជាក់លាក់មួយចំនួនដោយឈរលើមូលដ្ឋានថាៈ "វានឹងជាប្រយោជន៍នៃយុត្តិធម៌ដែលអនុញ្ញាតឲ្យមានការពន្យារពេលតាមវិធាន៧៣*ស្ទួន(ច)* សម្រាប់ការបង្ហាញសំណុំរឿងរបស់អយ្យការ ឆ្លើយតបទៅនឹងការបន្ថែមពេលវេលាដែលបានអនុញ្ញាតតាមសេចក្តីសម្រេចនេះ"[16]។ ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះក៏បានអនុញ្ញាតការបន្ថែមពេលវេលាដើម្បីឲ្យសួរដេញដោលសាក្សីនានាផងដែរ[17]។

*ខ. សាក្សីអត្តចរិត គឺដូចគ្នានឹងសាក្សីធម្មតា*

១១. តាមច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង គេពុំមានបទប្បញ្ញត្តិខាងផ្លូវច្បាប់ជាក់លាក់ដែលយោងទៅដល់និយមន័យ ឬដាក់កំហិតអំពីការសួរដេញដោលសាក្សីអត្តចរិកឡើយ។ វិធាន៨៧(១) នៃវិធានផ្ទៃក្នុងដែលតម្កល់គោលការណ៍នៃការវាយតម្លៃភស្តុតាងដោយសេរី[18] អនុញ្ញាតឲ្យអង្គជំនុំ

---

[13] *ដដែលដូចខាងលើ* ត្រង់វិធាន៩០(ច)៖ វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, វិធានស្តីពីនីតិវិធី និងភស្តុតាង, កំណត់សម្គាល់*ខាងដើម*លេខ ៥, វិធាន៩០(ច)។ វិធានស្តីពីនីតិវិធី និងភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា, កំណត់សម្គាល់*ខាងដើម*លេខ ៥, វិធាន៩០(ច)។

[14] តុលាការព្រហ្មទណ្ឌអន្តរជាតិ, បទបញ្ជាផ្ទៃក្នុងរបស់តុលាការ, បទបញ្ជាលេខ ៤៣, ២៦ ឧសភា ២០០៤។

[15] *រដ្ឋអាជ្ញា ទល់នឹង Mico Stanisic និង Stojan Zupljanin*, សេចក្តីសម្រេចផ្តល់មួយផ្នែកតាមសំណើរបស់អយ្យការដែលស្វែងរកពេលវេលាបន្ថែមសម្រាប់សាក្សីដែលនឹងត្រូវកោះហៅ អនុលោមតាមវិធាន៩២*ស្ទួនពីរ,* សំណុំរឿងលេខ: DT-08-91-T, ០២ មិថុនា ២០១០។

[16] *ដដែលដូចខាងលើ* ត្រង់កថាខណ្ឌទី៣៣។

[17] **E1/71.1** ប្រតិចារឹក, ២ ឧសភា ២០១២, ត្រង់ទំព័រទី៥៥-៥៧ (ផ្តល់ការអនុញ្ញាតនូវពេលវេលាបន្ថែមដើម្បីសួរដេញដោលសាក្សី ពាន ឃាន)។

[18] *ក្រមនីតិវិធីព្រហ្មទណ្ឌ* (កម្ពុជា), មាត្រា៣២១។ *Code de procedure pénale* (បារាំង), មាត្រា៤២៧។ សូមមើលផងដែរ J Pradel *Procédure pénale*, 13th ed (2006/7), s. 408។

ជម្រះស្តាប់បុគ្គលណាម្នាក់ក្នុងនាមជាសាក្សី។ គោលបំណងនៃការទទួលយកភ័ស្តុតាងជាឯកសារ និងសាក្សីគឺ "ដើម្បីនាំមកនូវការស្វែងរកការពិត"[19]។

១២. ស្រដៀងគ្នានេះ វិធានស្តីពីនីតិវិធីរបស់បណ្តាតុលាការអន្តរជាតិផ្សេងទៀត ក៏មិនមានចែង ឬដាក់កំហិត ខុសគ្នាអំពីការសួរដេញដោលសាក្សីអត្តចរិកដែរ។ វិធាន៨៩(គ) របស់តុលាការ ICTY និងវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTR ចែងថា៖ *"អង្គជំនុំជម្រះអាចទទួលយកភ័ស្តុតាងណាមួយដែលពាក់ព័ន្ធ ប្រសិនបើខ្លួនយល់ថា ភ័ស្តុតាងនោះមានតម្លៃជាប់ពាក់ព័ន្ធ"*[20]។ តុលាការ SCSL បានអនុម័តយកវិធានមួយដែលមានលក្ខណៈស្រដៀងគ្នាដ៏សំខាន់នេះ[21]។

១៣. ក្នុងរឿងក្តី *Kupreskic* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា ខ្លួនមានឆន្ទានុសិទ្ធិ ដើម្បីអនុញ្ញាតឲ្យសួរដេញដោលសាក្សីហួសពីសំណួរទាំងឡាយដែលពាក់ព័ន្ធនឹងអត្តចរិក ទោះបីការសួរដេញដោលសាក្សីពីដំបូងផ្តោតទៅលើតែបញ្ហាអត្តចរិកក៏ដោយ។ ក្នុងករណីនោះ មេធាវីការពារក្តីបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការសម្រេចដោយដាក់កំហិតការសួរសាក្សីម្នាក់ក្នុងចំណោមសាក្សីនានារបស់សហព្រះរាជអាជ្ញាចំពោះតែ "អ្វីដែលបានសួរក្នុងពេលសួរសាក្សីផ្ទាល់ខ្លួនដើម្បីរក្សាវិសាលភាពដែលបានកំហិត និងដ៏ចង្អៀតចំពោះការផ្តល់សក្ខីកម្មពីអត្តចរិក"[22]។ អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួនមានឆន្ទានុសិទ្ធិក្នុងការអនុញ្ញាតឲ្យមានការដេញដោលលើបញ្ហាបន្ថែមផ្សេងៗទៀត[23]។

១៤. លើសពីនេះទៀត ទម្លាប់អនុវត្តរបស់អន្តរជាតិមិនមានការកម្រិតកំណត់ចំពោះភាគីនានានៅក្នុងការសួរដេញដោលសាក្សី ដែលសួរសំនួរដេញដោលទៅកាន់សាក្សីដោយផ្ទាល់ក្នុងសវនាការនោះឡើយ ។ នៅឯតុលាការ ICTY ឧទាហរណ៍ដូចជា នៅក្នុងករណីរឿងក្តីរបស់ *Perisic* ខាងអយ្យការបានស្វែងរកសុំឲ្យចេញដីកាសម្រេចមួយច្រានចោលជាមុនមិនឲ្យមេធាវីការពារក្តីសួរដេញដោលសាក្សីខាងភាគីបដិបក្សលើ អង្គហេតុនៃការចោទប្រកាន់ផ្សេងៗ[24]។ អង្គជំនុំជម្រះ ដោយពឹង

[19] វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។

[20] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, វិធានស្តីពីនីតិវិធី និងភ័ស្តុតាង, ១៩ វិច្ឆិកា ២០១២, វិធាន៨៩(គ)។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា, វិធានស្តីពីនីតិវិធី និងភ័ស្តុតាង, វិធាន៨៩(គ), ០៩ កុម្ភៈ ២០១០។

[21] តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន, វិធានស្តីពីនីតិវិធី និងភ័ស្តុតាង, ២៧ ឧសភា ២០០៨, វិធាន៨៩(គ)។

[22] *រដ្ឋអាជ្ញា ទល់នឹង Zoran Kupreskic និងគូកន,* សេចក្តីសម្រេចស្តីពីការកំហិតវិសាលភាពនៃការសួរសាក្សីអត្តចរិករបស់ភាគីបដិបក្ខ, សំណុំរឿងលេខ: IT-95-16 សំណុំរឿងលេខ: IT-09-92-PT (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ២៦ កុម្ភៈ ១៩៩៩ ត្រង់២។

[23] *ដដែលដូចខាងលើ* ត្រង់២។

[24] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Momcilo Perisic.* សេចក្តីសម្រេចលើញត្តិរបស់អយ្យការដែលស្នើសុំឲ្យចេញសេចក្តីសម្រេចជាមុនមួយស្តីពីវិសាលភាពដែលអាចអនុញ្ញាតឲ្យបានសម្រាប់ការសួរដេញដោលសាក្សីខាងភាគីបដិបក្ស។ សំណុំរឿងលេខ IT-04-81-T (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី១២ មិថុនា២០០៦។

ផ្អែកលើករណីរឿងក្តីរបស់ *Krajisnik*[25] បានសម្រេចថា - ដោយត្រូវបានដាក់ឲ្យស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវស្តីពីភាពជាប់ទាក់ទងដែលមានអានុភាពគ្របដណ្តប់លើ - វិធានស្តីពីនិតិវិធីនិងភស្តុតាងមិនបានកំម្រិតកំណត់អំពីបញ្ហាទាំងឡាយ ដែលអាចត្រូវលើកឡើងនៅក្នុងអម្លុងនៃការសួរដេញដោលចំពោះសាក្សីខាងបដិបក្សនោះឡើយ[26]។ ក្នុងខណៈដែលសេចក្តីសម្រេចនេះបានលេចឡើងនៅក្នុងការដាក់ឲ្យដំណើរការនូវនីតិវិធីមួយ (a procedural setting) ដែលមានលក្ខណៈការខុសគ្នាខ្លះៗពីនីតិវិធីរបស់ អវតក សូមជូនជាយោបល់សម្រាប់ពិចារណាថា នៅក្នុងខ្លឹមសារ គោលការណ៍ដូចគ្នាតែមួយត្រូវបានយកមកអនុវត្តនៅទីនេះ - សាក្សីណាម្នាក់ដែលបានស្នើឡើងដោយភាគីណាមួយគួរតែបើកឲ្យភាគីផ្សេងៗទៀតសួរដេញដោល លើប្រធានបទពាក់ព័ន្ធនានាដែលស្ថិតនៅក្នុងរង្វង់ការដឹងរបស់ពួកគេ។ តាមការពិតទៅ នេះគឺជាទម្លាប់អនុវត្តកន្លងមករបស់អង្គជំនុំជម្រះសាលាដំបូងដែលទាក់ទងនឹងការសួរដេញដោលរបស់មេធាវីការពារក្តី អំពីរាល់សាក្សីទាំងអស់ដែលត្រូវបានស្នើឡើង និងពិនិត្យជាដំបូងគេដោយសហព្រះរាជអាជ្ញា។

### *គ. ការសួរដេញដោលអំពីអង្គហេតុពាក់ព័ន្ធ ទាំងមុន និងក្រោយ អម្លុងពេលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជាការចាំបាច់ត្រូវលើកជាតួយ៉ាងនូវភស្តុតាងភវនីយភាពចំពោះការចោទប្រកាន់នានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ*

១៥. សាក្សីអាចផ្តល់ភស្តុតាងអំពីអង្គហេតុដែលកើតឡើងនៅមុន និងក្រោយ អម្លុងពេលដែលគ្របដណ្តប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ សម្រាប់គោលបំណងមួយចំនួនដែលគេបានអនុញ្ញាត។ ឧទាហរណ៍ ដូចជានៅក្នុងរឿងក្តីនេះ ភស្តុតាងពាក់ព័ន្ធមានរួមបញ្ចូលនូវការចូលរួមចំណែករបស់ជនជាប់ចោទនៅក្នុងការបង្កើតគោលនយោបាយ និងផែនការនានាដែលនាំឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ និយាយដោយជាក់ស្តែង ការធ្វើផែនការពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានកើតឡើងនៅក្នុងអម្លុងពេល (ជាសប្តាហ៍ ជាខែ និង ជាឆ្នាំ) នៅមុនកាលបរិច្ឆេទនោះ។ នៅក្នុងន័យនោះ ភស្តុតាងជា "ប្រវត្តិសាវតារ" ស្ថិតនៅចំកណ្តាលបេះដូងនៃរឿងក្តីនេះ។ ដូចគ្នានេះដែរ ការប្រព្រឹត្តរបស់ជនជាប់ចោទនៅក្រោយការប្រព្រឹត្តឧក្រិដ្ឋកម្ម គឺមានការពាក់ព័ន្ធទៅនឹងទិដ្ឋភាពជាច្រើនយ៉ាង - ការណ៍នេះមានរួមបញ្ចូលទាំងការប្រព្រឹត្តដែលបង្កើតបានជា ការទទួលយកនូវការចូលរួមចំណែកនៅក្នុងឧក្រិដ្ឋកម្ម ឬមួយក៏ ការប្រព្រឹត្តដែលជាប់ពាក់ព័ន្ធទៅនឹងការកាត់ទោស (ឧទា. មគ្គុទ្ទេសក៍ជាបន្តទៀតរបស់បក្សកុម្មុយនីសកម្ពុជា និង ការចូលរួមជាមួយនឹងសហចារី ជាដើម)។

---

[25] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង MomCilo Krajisnik,*សំណុំរឿងលេខ IT-00-39-T, សេចក្តីសម្រេចស្តីពីការសួរដេញដោលសាក្សីខាងភាគីបដិបក្ស Milorad Davidovic, ចុះថ្ងៃទី១៥ ធ្នូ ២០០៥ ត្រង់កថាខណ្ឌទី៨។

[26] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Momcilo Perisic,* កំណត់សម្គាល់លេខ២៤ *ខាងដើម* ត្រង់លេខ៣៣។

១៦. ឧទាហរណ៍ដូចជា នៅក្នុង*ករណីរឿងក្តីរបស់* Bagosora *និងគូរកន* អង្គជំនុំជម្រះមួយរបស់តុលាការ ICTR បានសម្រេចថា ភស្តុតាងស្តីពីអត្ថិភាពនៃធាតុផ្សំនៃបទល្មើសតាមច្បាប់កំណត់ទាំងនៅមុនពេល ឬទាំងក្រោយអម្លុងពេលដែល គ្របដណ្តប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ អាចត្រូវបានបង្ហាញភស្តុតាងប្រយោជន៍ ដើម្បីជួយនៅក្នុងការបង្ហាញសក្ខីកម្មអំពីធាតុផ្សំនៃឧក្រិដ្ឋកម្មទាំងនោះ នៅក្នុងអម្លុងពេលដែលគ្របដណ្តប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ អង្គជំនុំជម្រះ បានបញ្ជាក់អំពីអត្តសញ្ញាណស្នូលនៃភាពខុសគ្នា "រវាងធាតុផ្សំនៃបទល្មើសណាមួយតាមច្បាប់កំណត់ ហើយនិង លក្ខខណ្ឌផ្សេងៗទៀតដែលច្បាប់តម្រូវ" ម្ខាង និងម្ខាងទៀត គឺ "ភស្តុតាងអំពីអត្ថិភាពនៃធាតុផ្សំបទល្មើស"[27]។ អង្គជំនុំជម្រះបានសម្រេចថា នៅក្នុងខណៈដែលអយ្យការមានភារៈទទួលខុសត្រូវក្នុងការបង្ហាញភស្តុតាងអំពីធាតុផ្សំផ្សេងៗនៃឧក្រិដ្ឋកម្មនានា និងអំពីលក្ខខណ្ឌតម្រូវដែលទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវដែលត្រូវមានវត្តមាន "នៅក្នុងពេលប្រព្រឹត្តនូវក្រិដ្ឋកម្មផ្សេងៗដែលត្រូវបានចោទប្រកាន់ដូចមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[28] នេះគឺមិនមែនមានន័យថា ភស្តុតាងអំពីអង្គហេតុនានានៅមុនពេល និងនៅក្រោយពេលដែលត្រូវបានគ្របដណ្តប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ("អង្គហេតុដែលស្ថិតនៅក្រៅពីវិសាលភាពនៃពេលវេលាកំណត់") មិនមានការជាប់ពាក់ព័ន្ធ ឬមិនអាចត្រូវបានលើកយកមកបង្ហាញដោយសមស្របសម្រាប់គោលបំណងមួយចំនួននោះឡើយ។

១៧. ពិសេសជាងនេះទៅទៀត អង្គជំនុំជម្រះ បានសម្រាប់ថា អង្គហេតុដែលមិនស្ថិតនៅក្នុងវិសាលភាពនៃពេលវេលាកំណត់ មុនអាចត្រូវបានបង្ហាញដើម្បីឲ្យឃើញអំពី *អត្ថិភាពនៅមុន ឬដែលមានជាបន្តមកទៀតនៃលក្ខណៈនៃធាតុផ្សំរបស់ឧក្រិដ្ឋកម្ម នៅពេលដែលមានអំពើឧក្រិដ្ឋណាមួយកំពុងតែបន្ត*[29]។ ឧទាហរណ៍ដូចជា បើសិនជាការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយមានរួមបញ្ចូលនូវធាតុផ្សំផ្សេងៗដែលទាក់ទងនឹងលក្ខណៈជាប្រព័ន្ធនៃការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មណាមួយ (ដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ), អង្គហេតុទាំងឡាយដែលមានតាំងពីមុនកាលបរិច្ឆេទ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងក្លាយជាភរនីយភាពសម្រាប់ឧក្រិដ្ឋកម្មនោះផ្ទាល់នៅក្នុងអម្លុងពេលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ស្រដៀងគ្នានេះដែរ អង្គហេតុដែលមិនស្ថិតនៅក្នុងវិសាលភាព នៃពេលវេលាកំណត់ អាចត្រូវបានប្រើធ្វើជាភស្តុតាងអំពី *អត្ថិភាពនៅមុន ឬដែលមានជាបន្តមកទៀតនៃលក្ខខណ្ឌដែលច្បាប់តម្រូវ ទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវ* ដូចជាភស្តុតាងអំពីគម្រោងផែនការឧក្រិដ្ឋកម្មណាមួយដែលកំពុងបន្តធ្វើនៅក្នុងបរិបទ ស្តីពីសហកម្មឧក្រិដ្ឋកម្មរួមដែលគម្រោងផែនការឧក្រិដ្ឋកម្មរួមមានប្រភពដើមចេញពីក្នុងនោះ នៅមុនពេលនៃឧក្រិដ្ឋកម្ម

---

[27] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Théoneste Bagosora និងគូរកន*, សំណុំរឿងលេខ ICTR-98-41-T, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃសក្ខីកម្មរបស់សាក្សី DBY ដែលបានស្នើសុំ, ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៣ ត្រង់ទំព័រ៦។

[28] *ដូចគ្នានឹងខាងលើ* ។

[29] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Théoneste Bagosora និងគូរកន*, សំណុំរឿងលេខ ICTR-98-41-T, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃសក្ខីកម្មរបស់សាក្សី DBY ដែលបានស្នើសុំ, ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៣ ត្រង់កថាខណ្ឌ៩។

ត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏ប៉ុន្តែបានបន្តទៅទៀតនៅក្នុងអម្លុងពេល ដែលគ្របដណ្តប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ[30]។

១៨. ការប្រព្រឹត្តអំពើឧក្រិដ្ឋរបស់ជនជាប់ចោទកាលពីមុន ដែលកើតឡើងនៅមុនអម្លុងពេលដូចនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំម្រះ អាចត្រូវបានបង្ហាញភស្តុតាង ដើម្បីឲ្យឃើញពីធាតុផ្សំខាងចេតនា ហើយក៏ដើម្បីឆ្លើយជំទាស់ទៅនឹងការលើកអំណះអំណាងសម្រាប់ការពារក្តីផងដែរ ជាពិសេសអំណះអំណាងសម្រាប់ការពារក្តីទាំងឡាយ ដែលមិនទទួលស្គាល់អំពីធាតុផ្សំខាងចេតនា នៃបទឧក្រិដ្ឋកម្ម។ នៅក្នុង*ករណីរឿងក្តីរបស់* Ngeze និង Nahimana មានភស្តុតាងអំពី*អំពើស្រដៀងគ្នានេះ* ត្រូវបានប្រព្រឹត្តនៅមុនអម្លុងពេលដែលបានគ្របដណ្តប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអាចត្រូវបានទទួលយកនៅក្រោមកាលៈទេសៈមួយចំនួន។ ដូចដែលលោកចៅក្រម Shahabuddeen បានធ្វើការគូសបញ្ជាក់៖ “ភស្តុតាងនៅមុនពេលដែលបទល្មើសនានាដើម្បីបង្ហាញភស្តុតាងអំពីគំរូជាតួយ៉ាង អំពីដំណើរការនៃការប្រព្រឹត្តរបស់ជនជាប់ចោទដែលត្រូវបានរៀបចំគម្រោង ឬដែលមានលក្ខណៈជាប្រព័ន្ធ ក្នុងករណីបើសិនជាការពន្យល់របស់គាត់ដោយផ្អែកលើមូលដ្ឋាននៃភាពគាប់ជួនគ្នា ដែលជាការប្រមាថមើលងាយចំពោះសុភនិច្ឆ័យ”[31]។ និយាយម្យ៉ាងទៀត ភស្តុតាងដែលជាអង្គហេតុស្រដៀងគ្នា អាចមានភាពជាប់ពាក់ព័ន្ធគ្នាយ៉ាងគ្រប់គ្រាន់ នៅពេលដែលបង្ហាញភស្តុតាងឲ្យឃើញអំពីចេតនា ឬដើម្បីធ្វើឲ្យលែងជឿចំពោះភស្តុតាងស្តីពីភាពគាប់ជួនគ្នា ឬស្តីពីកំហុស[32]។

១៩. ទូលំទូលាយជាងនេះទៅទៀត ទាក់ទងទៅនឹងបញ្ហានានាដែលទាក់ទងនឹងប្រវត្តិដើម ឬបរិបទដែលស្ថិតនៅក្រៅពីវិសាលភាពនៃអម្លុងពេលដែលគ្របដណ្តប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ភស្តុតាងអាចត្រូវបានបង្ហាញដើម្បីផ្តល់ជូនអង្គជំនុំជម្រះនូវការយល់ដឹងកាន់តែប្រសើរថែមទៀតអំពីឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់។ ក្នុងករណីរឿងក្តីរបស់ *Gatete និង Bagosora,* អង្គជំនុំជម្រះ របស់តុលាការ ICTR បានសម្រេចថា ការផ្តល់នូវព័ត៌មានបន្ថែមដែលទាក់ទងអំពីប្រវត្តិដើម ឬបរិបទនៃការចោទប្រកាន់ដែលប្រឆាំងនឹងជនជាប់ចោទ អាចត្រូវបានបង្ហាញភស្តុតាងដោយត្រឹមត្រូវ សូម្បីតែនៅពេលដែលជាប់ទាក់ទងជាមួយនឹងអង្គហេតុនានាដែលមិនស្ថិត

---

[30] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Théoneste Bagosora និងគូរកន*, សំណុំរឿងលេខ ICTR-98-41-T, សេចក្តីសម្រេចលើញត្តិរបស់ Bagosora ដែលសុំឲ្យលប់ចេញនូវភស្តុតាងដែលមិនស្ថិតនៅក្នុងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ចុះថ្ងៃទី១១ ឧសភា ឆ្នាំ២០០៧ ត្រង់កថាខណ្ឌទី៣១។

[31] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Hassan Ngeze និង Ferdinand Nahimana*, សំណុំរឿងលេខ ICTR-99-52-T, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្អំ, យោបល់ដាច់ដោយឡែកពីគ្នារបស់លោកចៅក្រម Shahabuddeen, ចុះថ្ងៃទី៥ កញ្ញា ២០០០, ត្រង់កថាខណ្ឌទី២០។

[32] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Théoneste Bagosora និងគូរកន*, សំណុំរឿងលេខ ICTR-98-41-T, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃសក្ខីកម្មរបស់សាក្សី DBY ដែលបានស្នើសុំ, ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៣ ត្រង់កថាខ័ណ្ឌ១៣។

នៅក្នុងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះក៏ដោយ[33]។ ជាឧទាហរណ៍ ព្រឹត្តការណ៍មួយអាចមិនមែនជាផ្នែកនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ប៉ុន្តែវាអាចជាការចាំបាច់ដើម្បីបានយល់ដឹងឲ្យបានពេញលេញអំពីឧក្រិដ្ឋកម្មនោះ។ ក្នុងករណីដូច្នេះ អង្គជំនុំជម្រះគួរទទួលយកភស្តុតាងអំពីអង្គហេតុនានា ដែលមិនស្ថិតនៅក្នុងវិសាលភាពពេលវេលាសាដីកាបញ្ជូនរឿងទៅជំនុំជម្រះ[34]។

## IV. អំណះអំណាង

២០. គឺជាការច្បាស់ណាស់ ដែលមកពី៖ (i) សេចក្តីសង្ខេបនៃចម្លើយរបស់សាក្សីដែលបានស្នើ។ (ii) ចម្លើយរបស់មេធាវីការពារក្តី ខៀវ សំផន។ (iii) សេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញា។ (iv) មគ្គុទេសក៍ណែនាំកាលពីមុនរបស់អង្គជំនុំជម្រះសាលាដំបូងថា សាក្សីទំនងជានឹងផ្តល់ភស្តុតាងដែលទាក់ ទងទៅនឹងអង្គហេតុនានាជាច្រើនដែលមាននៅក្នុងដីកាដំណោះស្រាយ ហើយដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០១ ដែលក្នុងនោះរួមទាំងអំពីតួនាទី និងមុខតំណែងរបស់ ខៀវ សំផន នៅមុនពេល ក្នុងពេល និងក្រោយពេលដែលគ្របដណ្តប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏ដូចជាអំពីប្រវត្តិបក្ស ជាទូទៅ។

២១. អាស្រ័យហេតុនេះ ភាគីទាំងឡាយគួរតែត្រូវបានអនុញ្ញាតឲ្យធ្វើការសួរដេញដោលចំពោះសាក្សីលើវិស័យនានាដែលមាននៅក្នុងដីកាដំណោះស្រាយ ករណីបើសិនជាសាក្សីអាចមានលទ្ធភាពឆ្លើយបានដោយផ្អែកលើមូលដ្ឋាន នៃបទពិសោធន៍របស់ខ្លួន កាលពីមុន ឬការដឹងដោយផ្ទាល់របស់ខ្លួន។ ច្បាប់ អវតក និងទម្លាប់អនុវត្តរបស់អន្តរជាតិគាំទ្រ និងលើកទឹកចិត្តចំពោះវិធីសាស្ត្រនេះ ដើម្បីធានាថា អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការបញ្ជាក់ការពិត អំពីការចោទប្រកាន់ទាំងឡាយដូចមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានដោយប្រសិទ្ធភាព។

---

[33] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Jean-Baptiste Gatete*, សំណុំរឿងលេខ ICTR-2000-61-PT, សេចក្តីសម្រេចលើញត្តិរបស់របស់មេធាវីដែលលើកឡើងអំពីវិការៈនៅក្នុងសេចក្តីសន្និដ្ឋានសង្ខេបមុនពេលសវនាការរបស់អយ្យការ ចុះថ្ងៃទី១៩ សីហា ២០០៩, ថ្ងៃទី២ តុលា ឆ្នាំ២០០៩ ត្រង់កថាខណ្ឌទី២៤។ *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Jean-Baptiste Gatete*, សំណុំរឿងលេខ ICTR-2000-61-T, សេចក្តីសម្រេចលើញត្តិរបស់មេធាវីដែលស្នើសុំឲ្យលុបចេញនូវភស្តុតាង និងការបង្ហាញដោយការគូរូបបញ្ជាក់អំពីករណីរបស់មេធាវី, ចុះថ្ងៃទី២៦ មីនា ២០១០ត្រង់កខាណ្ឌទី២៥។ *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Théoneste Bagosora និងគូរកន*, សំណុំរឿងលេខ ICTR-98-41-T, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃសក្ខីកម្មរបស់សាក្សី DBY ដែលបានស្នើសុំ, ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៣ ត្រង់កថាខ័ណ្ឌ១០។

[34] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Théoneste Bagosora និងគូរកន*, សំណុំរឿងលេខ ICTR-98-41-T, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃសក្ខីកម្មរបស់សាក្សី DBY ដែលបានស្នើសុំ, ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៣ ត្រង់កថាខ័ណ្ឌ១០។

២២. ទស្សនាទានស្ដីពីសាក្សីអំពី "អត្តចរិត" ណាម្នាក់ គឺជាពាក្យពេចន៍ដែលយកមកពីយុត្តាធិការរបស់ជាតិ ដែលដោះស្រាយទាក់ទងទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលកើតឡើងក្នុងក្របខណ្ឌនៃពេលវេលាដែលខ្លី តាមការប្រៀបធៀប។ នៅក្នុងបរិបទនេះ សាក្សី "អត្តចរិត" ណាម្នាក់ជាតួយ៉ាងគឺផ្ដល់ភស្តុតាងអំពីកិត្តិនាមរបស់ជនជាប់ចោទ។ ជាធម្មតា សាក្សីបានដឹងតិចតួចអំពីកាលៈទេសៈនានាដែលបណ្ដាលឲ្យមានការប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះ អំពីឧក្រិដ្ឋកម្មដោយផ្ទាល់ ឬអំពីកាលៈទេសៈ ការចូលរួម ជាមួយនឹងសហជនជាប់ចោទ ឬសហចារីឬអ្នកសមគំនិតដទៃៗទៀតបន្ទាប់ពីការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មទាំងនេះ។ សាក្សី "អត្តចរិក" បែបនេះគ្រាន់តែមានលទ្ធភាពអាចផ្ដល់សក្ខីកម្មបានតែអំពីកិត្តិនាមរបស់ជនជាប់ចោទ ដែលស្ថិតនៅក្រៅពីកាលៈទេសៈទាក់ទងនឹង អង្គហេតុ ដែលអាចនាំទៅរកការបង្ហាញភស្តុតាង ដែលនឹងជួយនៅក្នុងការបង្ហាញឲ្យឃើញ ឬ ការធ្វើឲ្យលែងជឿទៅលើភស្តុតាងអំពីឧក្រិដ្ឋកម្មទាំងនេះដោយផ្ទាល់តែប៉ុណ្ណោះ។

២៣. ការដែលដាក់ថា សាក្សី "អត្តចរិក" គឺមានសារៈប្រយោជន៍តិចតួចណាស់នៅក្នុងកិច្ចដំណើការនីតិវិធីនៃការជំនុំជម្រះក្ដីដែលទាក់ទងនឹងការចោទប្រកាន់ អំពីសហកម្មឧក្រិដ្ឋកម្មរួមដែលមានទ្រង់ទ្រាយធំ។ ជាពិសេស នេះគឺជាភស្តុតាង ក្នុងករណីបើសិនជា៖ (i) សហកម្មឧក្រិដ្ឋកម្មរួមត្រូវបានចោទប្រកាន់ថាបានមានអត្ថិភាព នៅមុនអម្លុងពេលដែលគ្របដណ្ដប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ និង (ii) ភស្តុតាងអំពីអត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួម និងអំពីតួនាទីរបស់ជនជាប់ចោទបន្ទាប់ពីអម្លុងពេលដែលគ្របដណ្ដប់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

២៤. ការរឹតត្បិតក្នុងការសួរដេញដោលអំពី "អត្តចរិក" របស់ ខៀវ សំផន ដោយសាក្សីអត្តចរិកតែមួយ និងដែលច្រានចោលខ្លឹមសារនៃការចោទប្រកាន់នានា ដូចដែលមាននៅក្នុងដីកាដំណោះស្រាយនោះ គឺជាបញ្ហា ដោយហេតុថា សាក្សីទាំងនេះមិនទាន់ត្រូវបានស្ដាប់ចម្លើយនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរទេ។ សាក្សីទាំងនេះមានតែមេធាវីការពារក្ដីបានទៅទាក់ទងជាមួយពួកគាត់តែប៉ុណ្ណោះ។ ភាគីផ្សេងទៀតមានសិទ្ធិស្របច្បាប់ ដើម្បីពិនិត្យពិច័យលើចំណេះដឹងរបស់សាក្សីទាំងនេះ ចំពោះការយល់ដឹងរបស់ពួកគាត់អំពីឧក្រិដ្ឋកម្មនានា និងការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មទាំងនេះនោះ ហួសពីអ្វីដែលបានផ្ដល់ដោយជនជាប់ចោទខ្លួនឯងផ្ទាល់ តាមរយៈមេធាវីរបស់ខ្លួននោះ។ គឺជាការច្បាស់ណាស់ថា មិនមែនជាការត្រឹមត្រូវនោះទេ ដែលភាគីមួយត្រូវបានច្រានចេញពីការសួរដេញដោលទៅលើអង្គហេតុនានាដែលពាក់ព័ន្ធដល់ការចោទប្រកាន់ នៅចំពោះមុខអង្គជំនុំជម្រះ។

២៥. ហេតុដូចនេះ ការសួររដេញដោលសាក្សីទាំងនេះ មិនគួរត្រូវបានកម្រិតត្រឹមតែបញ្ហានៃអត្តចរិតមួយមុខប៉ុណ្ណោះទេ។ ភាគីនានាគួរតែត្រូវបានផ្ដល់នូវពេលវេលាបន្ថែមសមរម្យ ដែលបានលៃលករួចហើយ ដើម្បីសួរដេញដោលចំពោះសាក្សីទាំងនេះលើគ្រប់បញ្ហាដែលពាក់ព័ន្ធទាំងអស់ទៅតាមចំណេះដឹងរបស់ពួកគាត់ ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ ។

## V. ដំណោះស្រាយដែលស្វែងរក

២៥. អាស្រ័យហេតុដូចបានលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះឱ្យអនុញ្ញាតស្តួរដេញដោលសាក្សីទាំង ០២រូប លើគ្រប់បញ្ហាទាំងអស់ដែលស្ថិតក្រោមចំណេះដឹងរបស់ពួកគាត់ និង សូមផ្តល់នូវពេលវេលាបន្ថែមទៀតដល់ភាគីនានាសម្រាប់សួរដេញដោលពួកគាត់ ឱ្យបានដល់បីម៉ោងជាសរុប សំរាប់សាក្សីទីមួយៗ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |